# សុន្ទរកថា

## ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី

## កែ គឹមយ៉ាន ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តំណាង

## ដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ

## ព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

## ប្រធានកាកបាទក្រហមកម្ពុជា

## ថ្លែងក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍

## ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ (លើកទី២៩ នៅកម្ពុជា)

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សាលសន្និសីទចតុម្មុខ, ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២

- **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- **លោកជំទាវ ពុំ ចន្ទីនី** អគ្គលេខាធិការកាកបាទក្រហមកម្ពុជា និងជាអនុប្រធានក្រុមការងារឥស្សរជនផ្ទើមថ្នាក់ជាតិ
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិការាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួងស្ថាប័ន
- ឯកឧត្តម លោកជំទាវ តំណាងអង្គទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា
- លោកស្រី Patricia Ongpin នាយិកាកម្មវិធីសហប្រជាជាតិរួមគ្នាស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ប្រចាំនៅកម្ពុជា
- ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ និងអន្តរជាតិ ព្រមទាំងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ក្មួយៗយុវជនទាំងអស់ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយសបំផុត និងមានសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានធ្វើជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចូលរួមជាមួយ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិក្មួយៗ នៅក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ ក្រោមប្រធានបទ "**ធ្វើឱ្យមានសមភាព**" ដ៏មហោឡារិកនាពេលនេះ បន្ទាប់ពីអាក់ខានប្រារព្ធពិធីនេះដោយផ្ទាល់អស់រយៈពេល០២ឆ្នាំ (ឆ្នាំ២០២០-ឆ្នាំ២០២១) ដោយសារបញ្ហាកូវីដ-១៩។ ក្នុងនាម **សម្តេចតេជោនាយករដ្ឋមន្ត្រី** ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** ដែល **សម្តេច** ក្នុងឋានៈជាឥស្សរជនផ្ទើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជាតែងតែដឹកនាំ និងចូលរួមដោយផ្ទាល់ក្នុងការពង្រឹកភាពផ្ទើមដល់បណ្តាញកាកបាទក្រហម គ្រប់លំដាប់ថ្នាក់នៅទូទាំងប្រទេសប្រឆាំងការរើសអើង ចំពោះអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ធ្វើឱ្យប្រសិទ្ធភាពនៃការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ នៅកម្ពុជាកាន់តែមានកម្រិតខ្ពស់ថែមទៀត។

ខ្ញុំក៏សូមពាំនាំនូវការកោតសរសើរ និងអរគុណពី **សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា** ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមការដឹកនាំរបស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ដែលបានធ្វើឱ្យសម្រេចនូវសមិទ្ធផលធំៗជាច្រើន ក្នុងការកាត់បន្ថយការរាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍នៅកម្ពុជា ជាពិសេសក្នុងស្ថានភាពដែលកម្ពុជា និងពិភពលោកបានជួបប្រទះនូវវិបត្តិកូវីដ-១៩ ក្នុងរយៈពេលកន្លងមកនេះ។ ខ្ញុំសូមថ្លែងនូវអំណរគុណចំពោះ សម្តេច ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្ថាប័នព្រឹទ្ធសភា រដ្ឋសភា កាកបាទក្រហមកម្ពុជា អង្គការសង្គមស៊ីវិល វិស័យសាសនា វិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការជាតិ អន្តរជាតិ និងបងប្អូនជនរួមជាតិទាំងអស់ ដែលបានចូលរួមគាំទ្រ និងខិតខំប្រឹងប្រែងយកអស់កំលាំងកាយចិត្ត ប្រាជ្ញាស្មារតីប្រកបដោយឆន្ទៈមោះមុត និងការប្តេជ្ញាខ្ពស់ធ្វើឱ្យការងារប្រយុទ្ធប្រឆាំងមេរោគអេដស៍ និងជំងឺអេដស៍

ទទួលបាននូវលទ្ធផលជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ ហើយយើងពិតជាមានក្តីសង្ឃឹមថា យើងអាចធ្វើដំណើរឆ្ពោះទៅសម្រេចបាននូវគោលដៅសូន្យបី និងគោលដៅ ៩៥ ៩៥ ៩៥ នាឆ្នាំ២០២៥ខាងមុខនេះ ទោះបីកម្ពុជាយើងបានទទួលរងនូវឥទ្ធិពលនៃបច្ច័យអវិជ្ជមានរបស់សកលលោក ដែលបានបង្កឡើងដោយការរីករាលដាលនៃជំងឺកូវីដ-១៩ សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន បញ្ហាថាមពលនិងការកើនឡើងអតិផរណា។ល។

ជាមួយគ្នានេះ ក្នុងនាម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ខ្ញុំសូមយកឱកាសនេះ ថ្លែងនូវការកោតសរសើរ និងអរគុណជាថ្មីម្តងទៀតចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកដោយមិននឿយហត់ក្នុងការរៀបចំ និងដឹកនាំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ព្រមទាំងការរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន(អាយប៉ា-AIPA)លើកទី៤៣ និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូកលើកទី៩ ទទួលបាននូវជោគជ័យយ៉ាងត្រចះត្រចង់ ដែលជាសក្ខីភាពមួយបានបង្ហាញថា នេះមិនមែនគ្រាន់តែជាជោគជ័យសម្រាប់ជំនាន់យើងប៉ុណ្ណោះទេ តែជាជោគជ័យជាប្រវត្តិសាស្ត្រសម្រាប់សហគមន៍អាស៊ាន ប្រទេសកម្ពុជា និងកូនចៅជំនាន់ក្រោយរបស់យើងថែមទៀត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗជាទីរាប់អាន!**

តាមរយៈសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងរបាយការណ៍របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ព្រមទាំងចំណាប់អារម្មណ៍របស់នាយិកាកម្មវិធីសហប្រជាជាតិរួមគ្នាស្តីពីមេរោគអេដស៍/ជំងឺអេដស៍ប្រចាំនៅកម្ពុជា (UNAIDS) តំណាងអង្គការសង្គមស៊ីវិល នៃគណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ រួមទាំងចំណាប់អារម្មណ៍របស់តំណាងបងប្អូនគ្រួសាររងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍ នាពេលមុននេះ គឺជាសក្ខីភាពជាក់ស្តែងមួយ ដែលបានបញ្ជាក់យ៉ាងច្បាស់ថា ទស្សនៈរបស់យើងក្នុងការកសាងសង្គមមួយដែលគ្មានការគំរាមកំហែងពីមេរោគអេដស៍ និងជំងឺអេដស៍អាចធ្វើទៅបាន និងមានន័យថា កម្ពុជាកំពុងតែស្ថិតនៅលើផ្លូវត្រូវ ដែលនឹងឈានទៅសម្រេចបាននូវ "**គោលដៅ ៩៥ ៩៥ ៩៥**" គឺ ៩៥% នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ៩៥% នៃអ្នកដែលដឹងស្ថានភាពផ្ទុកមេរោគអេដស៍ បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង៩៥% នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួន ដូចបានកំណត់ត្រឹមឆ្នាំ២០២៥ នៅក្នុងប្រទេសយើង និងនៅត្រឹមឆ្នាំ២០៣០ ដោយអង្គការសហប្រជាជាតិ។

នៅក្នុងរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២២នេះ ក៏បានបង្ហាញថា កម្ពុជាបានកាត់បន្ថយការចម្លងមេរោគអេដស៍ថ្មីបានពី២.៣០០នាក់ ក្នុងឆ្នាំ២០១០ មកត្រឹមចំនួនប៉ាន់ស្មានប្រហែល ១.១០០នាក់ ក្នុងឆ្នាំ២០២១។ នៅត្រីមាសទី៣ ឆ្នាំ២០២២នេះ អ្នកផ្ទុកមេរោគអេដស៍ចំនួន៦៤ ១៨៤នាក់(ប្រមាណ៩៩%) បានទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍

ដោយឥតគិតប្រាក់ពីមន្ទីរពេទ្យរដ្ឋ ដែលជាលទ្ធផលបានធ្វើឱ្យអត្រាមរណភាពដោយសារជំងឺអេដស៍បន្តធ្លាក់ចុះជារៀងរាល់ឆ្នាំ។ ការឆ្លងមេរោគអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់មានការធ្លាក់ចុះគួរឱ្យសម្គាល់ពីអត្រាប្រមាណ២៤,៨%នៅឆ្នាំ២០១២ មកនៅអត្រាប្រមាណ១៥,២%ក្នុងឆ្នាំ២០១៧។ សន្ទស្សន៍នៃការរើសអើង មើលងាយអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍មានការថយចុះខ្លាំង គួរជាទីមោទនៈ។

ទាំងនេះ គឺជាជោគជ័យដ៏ត្រចះត្រចង់ ដែលយើងសម្រេចបាននាពេលកន្លងមក ប៉ុន្តែស្ថានភាពនៃបញ្ហារាលដាលមេរោគអេដស៍/ជំងឺអេដស៍ ក៏នៅតែមានភាពផុយស្រួយនៅឡើយ។ ក្នុងន័យនេះ ប្រសិនបើយើងធ្វេសប្រហែសតែបន្តិច ការរាលដាលមេរោគអេដស៍នឹងអាចផ្ទុះឡើងវិញ ដែលពិបាកនឹងគ្រប់គ្រងជាងមុនៗទៅទៀត ជាពិសេសការផ្ទុះឡើងនៅក្នុងចំណោមប្រជាជនប្រឈមមុខខ្ពស់រួមមាន ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមស្ត្រីបម្រើការងារក្នុងគ្រឹះស្ថានកំសាន្តសប្បាយ ក្រុមយុវវ័យ ក្រុមអ្នកប្រើប្រាស់ និងចាក់គ្រឿងញៀនជាដើម។ នៅឆ្នាំ២០២១ អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានប្រមាណ១៣,៦% ដែលជាអត្រាខ្ពស់មួយដែលត្រូវយកចិត្តទុកដាក់។ ការឆ្លងមេរោគអេដស៍ ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនទូទៅមានអត្រា៤% នៅឆ្នាំ២០១២ និងអត្រាប្រមាណ៥,៧% ក្នុងឆ្នាំ២០១៧។*(ក្នុងរយៈពេល៩ខែ ឆ្នាំ២០២២ អ្នកប្រើប្រាស់គ្រឿងញៀនសរុបមានចំនួន១៧.៩៩៦នាក់ ដែលក្នុងនោះអ្នកដែលបានធ្វើសមាហរណកម្មចេញពីមណ្ឌល មាន៩.៦២៨ នាក់ អ្នកដែលបន្តធ្វើការបន្សាបព្យាបាលនៅតាមមណ្ឌល មាន ៤.៦៨៦នាក់ អ្នកដែលបានមកទទួលសេវាពិនិត្យព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈក្នុងរាជធានី ខេត្ត មាន៣.២៥៤នាក់ និងអ្នកប្រើប្រាស់គ្រឿងញៀនដែលបានចាត់បញ្ជូនទៅតុលាការមាន៤២៨នាក់។ អ្នកប្រើគ្រឿងញៀនដោយចាក់មានចំនួន ៨៧០ នាក់ ស្មើនឹង ៤.៨៣% នៃចំនួនអ្នកញៀនគ្រឿងញៀនសរុប)*

ដូចនេះ សូមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញប្រជាជនគន្លឹះ ក៏ដូចជាបងប្អូនជនរួមជាតិទាំងអស់ បន្តការយកចិត្តទុកដាក់ឱ្យបានខ្ពស់ និងចូលរួមឱ្យបានកាន់តែសកម្មថែមទៀតជាមួយរាជរដ្ឋាភិបាល ដើម្បីដោះស្រាយហានិភ័យខាងលើឱ្យមានប្រសិទ្ធភាព និងទាន់ពេលក្នុងដំណើរការឆ្ពោះទៅបញ្ចប់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នាឆ្នាំ២០២៥។ ការបញ្ចប់បញ្ហាអេដស៍ដែលជាការគំរាមកំហែងដល់សុខភាពសាធារណៈ គឺជាជោគជ័យមួយក្នុងការរួមចំណែកលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ កសាងសេដ្ឋកិច្ចគ្រួសារ សហគមន៍ និងប្រទេសជាតិឱ្យមានការវិវត្តន៍រីកចម្រើនឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងប្រទេសឱ្យក្លាយទៅជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។*(ចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដល់ ខែតុលា ឆ្នាំ២០២២ មានគ្រួសារក្រ១និងក្រ២ ចំនួន ៧០៦ ០៦០គ្រួសារ ទទួលបានការឧបត្ថម្ភសាច់ប្រាក់ពីរាជរដ្ឋាភិបាល ក្នុងអំឡុងពេលកូវីដ-១៩ សរុបទឹកប្រាក់ចំនួន ៨៣៧លាន ៥ម៉ឺនដុល្លារ និងដោយឡែកអ្នកផ្ទុកមេរោគអេដស៍ចំនួន ៦៦១៧នាក់ ទទួលបានប័ណ្ណមូលនិធិសមធម៌)*។

**អង្គពិធីទាំងមូលជាទីមេត្រី!**

ក្នុងដំណើរឆ្ពោះទៅសម្រេចគោលដៅលុបបំបាត់ជំងឺអេដស៍ និងធ្វើឱ្យមាននិរន្តរភាព និងចីរភាពកម្មវិធីអេដស៍នៅកម្ពុជា គឺពិតជាមានការលំបាក និងស្មុគស្មាញមែន ប៉ុន្តែយើងអាចធ្វើបានតាមរយៈការដឹកនាំ ការគ្រប់គ្រង ការសម្របសម្រួល និងការចូលរួមពីគ្រប់សមាសភាពសង្គមប្រកបដោយការប្តេជ្ញាចិត្តយ៉ាងមោះមុតរួមគ្នា និងជម្នះឱ្យបាននូវរាល់ឧបសគ្គនានា ដែលអាចកើតមានឡើង ដូចជា៖ កត្តាវើសអើង កត្តាធនធាន នវានុវត្តន៍ និងបរិយាប័ន្នជាដើម។ ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រកាសជាឱឡារិកថា រាជរដ្ឋាភិបាលកម្ពុជា នៅតែចាត់ទុកការងារប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា ជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលុបបំបាត់អេដស៍នៅឆ្នាំ២០២៥ ។

ឆ្លៀតក្នុងឱកាសចូលរួមអបអរសាទរទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២២នេះ ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមផ្តល់នូវការណែនាំបន្ថែមមួយចំនួនដូចតទៅ៖

ទី១.អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវបន្តអនុវត្តដោយម៉ឺងម៉ាត់ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ ដែលជាផែនទីចង្អុលផ្លូវតែមួយគត់សម្រាប់ការងារប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ដែលដឹកនាំអនុវត្តដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយផ្អែកលើសរសរស្តម្ភទាំងបីរួមមាន ១. ការដឹកនាំ និងភាពជាម្ចាស់ ២. ភាពជាដៃគូ និង ៣. ការវិនិយោគ ដើម្បីជានាភាពជោគជ័យ និងនិរន្តរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ទី២.អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្រសួងសុខាភិបាល រួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការទាំងប្រាំមួយ ដូចមានចែងក្នុងលិខិតលេខ ២១៣ សជណ.សស ចុះ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ទី៣.ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី និងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមជំរុញការអប់រំ ផ្សព្វផ្សាយអំពីមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីបង្ការការចម្លងមេរោគអេដស៍ក្នុងសហគមន៍ជាពិសេសក្រុមប្រជាជនគន្លឹះរួមមាន ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមអ្នកប្រើប្រាស់និងចាក់គ្រឿងញៀន ក្រុមស្ត្រីបម្រើការងារក្នុងគ្រឹះស្ថានកំសាន្តសប្បាយ និងក្រុមយុវវ័យទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

ទី៤.អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវបន្តសហការជាមួយក្រសួងសុខាភិបាលធ្វើការសិក្សារៀបចំយន្តការ និងយុទ្ធសាស្ត្រអន្តរាគមន៍ក្នុងការលុបបំបាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅត្រឹមឆ្នាំ២០២៥។ ជាមួយនេះ ក៏ត្រូវបន្តពង្រឹង និងបង្កើនកិច្ចសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាបន្ថែមទៀត ដើម្បីបង្ការ និងទប់ស្កាត់ឱ្យកាន់តែមានប្រសិទ្ធភាពនូវការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់និងអ្នកចាក់គ្រឿងញៀន។

ទី៥. ក្រោមការដឹកនាំ សម្របសម្រួល របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ ត្រូវបន្តសហការរៀបចំគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ ២០២៣-២០២៨ ឱ្យបានទាន់ពេលតាមលិខិតលេខ ៩២៧ សជណ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការក្រុមការងារបច្ចេកទេសតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣២០២៨- របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍លើកទី៦ តាមប្រព័ន្ធជាតិប្រកបដោយនិរន្តរភាព និងចីរភាព។

ទី៦.អភិបាលរាជធានី ខេត្ត ត្រូវបន្តពង្រឹងយន្តការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានទូទាំងប្រទេសដើម្បីទទួលខុសត្រូវក្នុងភាពជាម្ចាស់ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព។

ទី៧.ចំពោះបងប្អូនដែលសង្ស័យថាបានឆ្លងមេរោគអេដស៍ ត្រូវរួសរាន់មកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ដើម្បីឆាប់ទទួលបានការព្យាបាល ថែទាំ និងរក្សាសុខភាពបានល្អប្រសើរ។

ទី៨.គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ អង្គការសង្គមស៊ីវិល ដៃគូជាតិ អន្តរជាតិទាំងអស់ ត្រូវបន្តជួយសហការគាំទ្រ និងលើកទឹកដល់អ្នកផ្ទុកមេរោគអេដស៍ ជំងឺអេដស៍តាមគ្រប់មធ្យោបាយ និងរូបភាព ដើម្បីសុខដុមនីយកម្មសហគមន៍ និងគ្រួសារ។

ទី៩.ត្រូវបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ការជួញដូរមនុស្ស និងល្បែងស៊ីសងខុសច្បាប់តាមគ្រប់រូបភាព។ ត្រូវបន្តអនុវត្តវិធានការពាក់ ៣ ការពារ និងរួមគ្នាចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដើម្បីប្រយុទ្ធប្រឆាំងនិងការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតាមអង្គភាពការងារ និងសហគមន៍យើង។ ជាមួយគ្នានេះ ខ្ញុំសូមអំពាវនាវប្រជាពលរដ្ឋទាំងអស់ដែលគ្រប់អាយុបោះឆ្នោត ដែលពុំទាន់បានចុះឈ្មោះបោះឆ្នោតត្រូវប្រញាប់រួសរាន់ទៅចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតនៅតាមឃុំ-

សង្កាត់ ឱ្យបានគ្រប់ៗគ្នាតាមការអំពាវនាវរបស់ គ.ជ.ប ដែលនឹងផុតកំណត់នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ ខាងមុខនេះ ដើម្បីបំពេញសិទ្ធិ និងកាតព្វកិច្ចជាប្រជាពលរដ្ឋឱ្យបានគ្រប់ៗគ្នា។

ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំសូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ អង្គការសង្គមស៊ីវិលនានា វិស័យសាសនា វិស័យឯកជន សិល្បករ ពិធីករ កីឡាករ ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមចូលរួមជាមួយរាជរដ្ឋា-ភិបាលកម្ពុជា ក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់នូវការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។ ជាមួយគ្នានេះ ខ្ញុំក៏សូមអំពាវនាវដល់សហគមន៍អន្តរជាតិ ដៃគូអភិវឌ្ឍនានា សូមបន្តជួយគាំទ្រជាបច្ចេកទេស និងហិរញ្ញវត្ថុ ដល់សកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យកម្ពុជាយើងខ្ញុំអាចឈានទៅសម្រេចបានតាមគោលដៅលុបបំបាត់អេដស៍ឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបនឹងអេដស៍ឆ្នាំ២០២៣-២០២៨ និងឆ្នាំបន្តបន្ទាប់តទៅ។

ជាទីបញ្ចប់ និងនៅក្នុងឱកាសឆ្នាំថ្មី ឆ្នាំសកល២០២៣ ដែលនឹងឈានមកដល់ខាងមុខនេះ ខ្ញុំសូមប្រគេនពរ និងប្រសិទ្ធពរជូន សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្មួយៗយុវជន និងអង្គពិធីទាំងមូល សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសជាឱឡារិកថា "**យើងរួមគ្នា ធ្វើឱ្យមានសមតាព ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា**"។

*សូមអរគុណ!*